ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងពាណិជ្ជកម្ម

លេខ ១៧៨ ព.ណ.ប្រ.ក.សរស.ប្រក

# ប្រកាស

## ស្តីពី

## នីតិវិធីនៃការជូនដំណឹងជាក្រោយនៃការរួមបញ្ចូលគ្នានៃធុរកិច្ច

## រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០២១/០១៣ ចុះថ្ងៃទី៥ ខែតុលា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការប្រកួតប្រជែង
- បានឃើញអនុក្រឹត្យលេខ៣៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ៣៧ អនក្រ.បក ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការប្រកួតប្រជែងកម្ពុជា
- បានឃើញអនុក្រឹត្យលេខ៦០ អនក្រ.បក ចុះថ្ងៃទី៦ ខែមីនា ឆ្នាំ២០២៣ ស្តីពីលក្ខខណ្ឌនិងនីតិវិធីអំពីការរួមបញ្ចូលគ្នានៃធុរកិច្ច
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងពាណិជ្ជកម្ម



ឡូត៍លេខ ១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ / ទូរសារៈ (៨៥៥)-២៣ ៨៦៦ ៤៦៩
Lot 19-61,Russian Federation Blvd, Phum Teuk Thla, Sangkat Teuk Thla, Khan Sen Sok, Phnom Penh, Kingdom of CAMBODIA Phone/Facsimile: (855)-23 866 469

## សម្រេច

**ប្រការ១.-**

ប្រកាសនេះកំណត់អំពីនីតិវិធីនៃការជូនដំណឹងអំពីការរួមបញ្ចូលគ្នានៃធុរកិច្ច ដែលមានកាតព្វកិច្ចជូនដំណឹងជាក្រោយ ក្នុងគោលបំណងផ្តល់នូវការទទួលស្គាល់និងភាពស្របច្បាប់ក្នុងការរួមបញ្ចូលគ្នានៃធុរកិច្ច។

**ប្រការ២.-**

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះការរួមបញ្ចូលគ្នានៃធុរកិច្ចដែលមានកាតព្វកិច្ចជូនដំណឹងជាក្រោយ ដូចមានចែងក្នុងមាត្រា១៣នៃអនុក្រឹត្យលេខ៦០ អនក្រ.បក ចុះថ្ងៃទី៦ ខែមីនា ឆ្នាំ២០២៣ ស្តីពីលក្ខខណ្ឌនិងនីតិវិធីអំពីការរួមបញ្ចូលគ្នានៃធុរកិច្ច។

**ប្រការ៣.-**

ភាគីរួមបញ្ចូលគ្នានៃធុរកិច្ចដែលមានកាតព្វកិច្ចជូនដំណឹងជាក្រោយ ដូចមានចែងក្នុងប្រការ៤នៃប្រកាសនេះ ត្រូវជូនដំណឹងអំពីការរួមបញ្ចូលគ្នានៃធុរកិច្ចមកគណៈកម្មាធិការប្រកួតប្រជែងកម្ពុជា «គ.ប.ក.» ក្នុងរយៈពេល ៣០ (សាមសិប)ថ្ងៃនៃថ្ងៃធ្វើការ ក្រោយពីការបញ្ចប់ផ្នែកសំខាន់ៗនៃការរួមបញ្ចូលគ្នានៃធុរកិច្ច ដូចមានចែងក្នុងមាត្រា១៣នៃអនុក្រឹត្យស្តីពីលក្ខខណ្ឌនិងនីតិវិធីអំពីការរួមបញ្ចូលគ្នានៃធុរកិច្ច និងប្រការ៥នៃប្រកាសនេះ។

**ប្រការ៤.-**

ភាគីរួមបញ្ចូលគ្នានៃធុរកិច្ចណាដែលមិនមានកាតព្វកិច្ចជូនដំណឹងជាមុន ដូចមានចែងក្នុងជំពូកទី២នៃអនុក្រឹត្យស្តីពីលក្ខខណ្ឌនិងនីតិវិធីអំពីការរួមបញ្ចូលគ្នានៃធុរកិច្ច ត្រូវធ្វើការជូនដំណឹងជាក្រោយ ក្នុងករណីកម្រិតកំណត់ ស្មើឬលើសពី ៥០ (ហាសិប)ភាគរយនៃកម្រិតកំណត់ ដូចមានចែងក្នុងប្រការ៣ ប្រការ៤ និងប្រការ៥នៃសេចក្តីសម្រេចលេខ០៩៥ ព.ណ អ.កបប.សសរ ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០២៣ ស្តីពីកម្រិតកំណត់នៃការជូនដំណឹងជាមុនអំពីការរួមបញ្ចូលគ្នានៃធុរកិច្ច។

លក្ខខណ្ឌដូចមានចែងក្នុងកថាខណ្ឌទី១ខាងលើ ត្រូវបានអនុវត្តដូចគ្នា ក្នុងករណីមានវិសោធនកម្មលើសេចក្តីសម្រេចលេខ០៩៥ ព.ណ អ.កបប.សសរ ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០២៣ ស្តីពីកម្រិតកំណត់នៃការជូនដំណឹងជាមុនអំពីការរួមបញ្ចូលគ្នានៃធុរកិច្ច។

**គ.ប.ក.** អាចធ្វើការកែប្រែកម្រិតកំណត់សម្រាប់ការជូនដំណឹងជាក្រោយ ដូចមានចែងក្នុងកថាខណ្ឌទី១ខាងលើ ស្របតាមស្ថានភាពជាក់ស្តែង។

**ប្រការ៥.-**

ភាគីមួយក្នុងចំណោមភាគីជូនដំណឹងនៃការរួមបញ្ចូលគ្នានៃធុរកិច្ចដែលមានកាតព្វកិច្ចជូនដំណឹងជាក្រោយ បន្ទាប់ពីបានបញ្ចប់នីតិវិធីនៃការរួមបញ្ចូលគ្នានៃធុរកិច្ច ត្រូវដាក់ពាក្យជូនដំណឹងមក **គ.ប.ក.** ដោយភ្ជាប់មកជាមួយឯកសារនិងព័ត៌មានតម្រូវ ស្របតាមការកំណត់ដូចមានចែងក្នុងទម្រង់ពាក្យជូនដំណឹងជាក្រោយនៃការរួមបញ្ចូលគ្នានៃធុរកិច្ច (ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធនៃប្រកាសនេះ)។

ទម្រង់ពាក្យជូនដំណឹងជាក្រោយនៃការរួមបញ្ចូលគ្នានៃធុរកិច្ច ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធនៃប្រកាសនេះ អាចធ្វើការកែសម្រួលតាមការសម្រេចរបស់ **គ.ប.ក.** ក្នុងករណីចាំបាច់។

អគ្គនាយកដ្ឋានការពារអ្នកប្រើប្រាស់ កិច្ចការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំ «ក.ប.ប.» ជាលេខាធិការដ្ឋានរបស់ **គ.ប.ក.** ក្នុងការទទួលពាក្យជូនដំណឹងជាក្រោយនៃការរួមបញ្ចូលគ្នានៃធុរកិច្ច។

**ប្រការ៦.-**

ភាគីជូនដំណឹងជាក្រោយនៃការរួមបញ្ចូលគ្នានៃធុរកិច្ច ត្រូវផ្តល់ឯកសារនិងព័ត៌មានដូចខាងក្រោម៖

ក- ពាក្យជូនដំណឹងជាក្រោយនៃការរួមបញ្ចូលគ្នានៃធុរកិច្ច។

ខ- ច្បាប់ចម្លងលិខិតបញ្ជាក់កាតព្វកិច្ចសារពើពន្ធពីអគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

គ- ច្បាប់ចម្លងឯកសារបញ្ជាក់អំពីការចុះបញ្ជីពាណិជ្ជកម្មនិងឯកសារពាក់ព័ន្ធដល់ការផ្លាស់ប្តូរកម្មសិទ្ធិនៅក្រសួងពាណិជ្ជកម្ម និងក្រសួង ស្ថាប័នពាក់ព័ន្ធ។

ឃ-ច្បាប់ចម្លងឯកសារពីបញ្ញត្តិករ ឬក្រសួង ស្ថាប័នមានសមត្ថកិច្ចក្នុងវិស័យពាក់ព័ន្ធនឹងការស្នើសុំការរួមបញ្ចូលគ្នានៃធុរកិច្ច (ប្រសិនបើមាន)។

ង- ច្បាប់ចម្លងវិក្កយបត្របង់ប្រាក់ការជូនដំណឹងជាក្រោយនៃការរួមបញ្ចូលគ្នានៃធុរកិច្ច។

**ប្រការ៧.-**

ក្រោយពីទទួលបានពាក្យជូនដំណឹងជាក្រោយនៃការរួមបញ្ចូលគ្នានៃធុរកិច្ច ដូចមានចែងក្នុងប្រការ៥ នៃប្រកាសនេះ អគ្គនាយកដ្ឋាន **ក.ប.ប.** មានរយៈពេល ៧ (ប្រាំពីរ)ថ្ងៃនៃថ្ងៃធ្វើការ ក្នុងការចេញសេចក្តីជូនដំណឹងទៅភាគីជូនដំណឹងជាក្រោយនៃការរួមបញ្ចូលគ្នានៃធុរកិច្ចអំពីការបំពេញកាតព្វកិច្ចជូនដំណឹងជាក្រោយនៃការរួមបញ្ចូលគ្នានៃធុរកិច្ច ដូចមានចែងក្នុងមាត្រា១៣នៃអនុក្រឹត្យស្តីពីលក្ខខណ្ឌនិងនីតិវិធីអំពីការរួមបញ្ចូលគ្នានៃធុរកិច្ច ឬបញ្ជាក់ភាពមិនត្រឹមត្រូវនិងមិនគ្រប់គ្រាន់នៃឯកសារនិងព័ត៌មានដែលផ្តល់មក **គ.ប.ក.**។

បន្ទាប់ពីទទួលបានសេចក្តីជូនដំណឹងពីអគ្គនាយកដ្ឋាន **ក.ប.ប.** អំពីភាពមិនត្រឹមត្រូវនិងមិនគ្រប់គ្រាន់នៃឯកសារនិងព័ត៌មានដែលផ្តល់មក **គ.ប.ក.** ភាគីជូនដំណឹងជាក្រោយមានរយៈពេល ១៥ (ដប់ប្រាំ)ថ្ងៃនៃថ្ងៃធ្វើការក្នុងការផ្តល់ឯកសារនិងព័ត៌មានតម្រូវបន្ថែមដើម្បីបញ្ជាក់ពីភាពត្រឹមត្រូវនិងគ្រប់គ្រាន់។ ប្រសិនបើភាគីជូនដំណឹងជាក្រោយមិនបានផ្តល់ឯកសារនិងព័ត៌មាន ក្នុងរយៈពេលកំណត់នោះទេ ការជូនដំណឹងជាក្រោយនៃការរួមបញ្ចូលគ្នានៃធុរកិច្ចត្រូវចាត់ទុកជាមោឃៈ។ ក្នុងករណីនេះ ភាគីជូនដំណឹងជាក្រោយត្រូវធ្វើការជូនដំណឹងជាក្រោយនៃការរួមបញ្ចូលគ្នានៃធុរកិច្ចសារជាថ្មីមក **គ.ប.ក.**។

អគ្គនាយកដ្ឋាន **ក.ប.ប.** អាចចេញសេចក្តីជូនដំណឹងទៅភាគីជូនដំណឹងជាក្រោយនៃការរួមបញ្ចូលគ្នានៃធុរកិច្ច ក្នុងការពន្យារពេល ដូចមានចែងក្នុងកថាខណ្ឌទី២ខាងលើពីភាគីជូនដំណឹងជាក្រោយនៃការរួមបញ្ចូលគ្នានៃធុរកិច្ច ដោយមានមូលហេតុសមស្រប។

**ប្រការ៨.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៩.-**

សមាសភាពគណៈកម្មាធិការប្រកួតប្រជែងកម្ពុជា នាយកខុទ្ទកាល័យ ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានការពារអ្នកប្រើប្រាស់ កិច្ចការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំ និងប្រធានគ្រប់អង្គភាពពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃពុធ ១១រោច ខែជេស្ឋ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០២៣

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**និងជាប្រធានគណៈកម្មាធិការប្រកួតប្រជែងកម្ពុជា**

**ប៉ាន_សូរស័ក្តិ**

**កន្លែងទទួល:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- រដ្ឋបាលរាជធានី ខេត្ត
- ដូចប្រការ៩
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ឧបសម្ព័ន្ធ

គណៈកម្មាធិការប្រកួតប្រជែងកម្ពុជា
"គ.ប.ក."

# ពាក្យស្នើសុំជូនដំណឹងជាក្រោយ
# នៃការរួមបញ្ចូលគ្នានៃធុរកិច្ច

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ.................................. ជាអក្សរពុម្ពឡាតាំង........................................................
កាន់អត្តសញ្ញាណបណ្ណ/លិខិតឆ្លងដែន លេខ............................ ចុះថ្ងៃទី......... ខែ.......... ឆ្នាំ.............
ជនជាតិ..................... សញ្ជាតិ................... អាសយដ្ឋាន...........................................................
......................................................................................................................................
លេខទូរស័ព្ទ.......................................អ៊ីម៉ែល...................................................................
តួនាទី.......................... ជាតំណាងសហគ្រាស/ក្រុមហ៊ុន.....................................................
ទីស្នាក់ការ.......................................................................................................................
លេខទូរស័ព្ទ.......................................អ៊ីម៉ែល...................................................................

**សូមគោរពជូន**

**ឯកឧត្តមរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម និងជាប្រធានគណៈកម្មាធិការប្រកួតប្រជែងកម្ពុជា**

**កម្មវត្ថុ ៖** សំណើស្នើសុំជូនដំណឹងជាក្រោយនៃការរួមបញ្ចូលគ្នានៃធុរកិច្ច

តបតាមកម្មវត្ថុខាងលើ ខ្ញុំបាទ/នាងខ្ញុំ.............................................................. សូមគោរពជម្រាបជូន **ឯកឧត្តមរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម និងជាប្រធានគណៈកម្មាធិការប្រកួតប្រជែងកម្ពុជា** មេត្តាជ្រាបថា ដើម្បីបំពេញនីតិវិធីដូចមានចែងក្នុងអនុក្រឹត្យស្តីពីលក្ខខណ្ឌនិងនីតិវិធីអំពីការរួមបញ្ចូលគ្នានៃធុរកិច្ច សហគ្រាស/ក្រុមហ៊ុនរបស់ខ្ញុំបាទ/នាងខ្ញុំ សូមគោរពស្នើសុំជូនដំណឹងជាក្រោយនៃការរួមបញ្ចូលគ្នានៃធុរកិច្ច ដោយភ្ជាប់មកជាមួយនូវឯកសារនិងព័ត៌មានដូចខាងក្រោម៖

ក- ច្បាប់ចម្លងលិខិតបញ្ជាក់កាតព្វកិច្ចសារពើពន្ធពីអគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (១ច្បាប់)

ខ- ច្បាប់ចម្លងឯកសារបញ្ជាក់អំពីការចុះបញ្ជីពាណិជ្ជកម្មនិងឯកសារពាក់ព័ន្ធដល់ការផ្លាស់ប្តូរកម្មសិទ្ធិនៅក្រសួងពាណិជ្ជកម្ម និងក្រសួង ស្ថាប័នពាក់ព័ន្ធ (១ច្បាប់)

គ- ច្បាប់ចម្លងឯកសារពីបញ្ញត្តិករ ឬក្រសួង ស្ថាប័នមានសមត្ថកិច្ចក្នុងវិស័យពាក់ព័ន្ធនឹងការស្នើសុំការរួមបញ្ចូលគ្នានៃធុរកិច្ច (ប្រសិនបើមាន) (១ច្បាប់)

ឃ-ច្បាប់ចម្លងវិក្កយបត្របង់ប្រាក់ការជូនដំណឹងជាក្រោយនៃការរួមបញ្ចូលគ្នានៃធុរកិច្ច (១ច្បាប់)

ង-លិខិតប្រគល់សិទ្ធិ (ក្នុងករណីជាតំណាងសហគ្រាស/ក្រុមហ៊ុន) (១ច្បាប់)។

ខ្ញុំបាទ/នាងខ្ញុំ សូមធានាអះអាងថាឯកសារនិងព័ត៌មានទាំងអស់ដែលខ្ញុំផ្តល់ជូនក្នុងពាក្យស្នើសុំជូនដំណឹងជាក្រោយនៃការរួមបញ្ចូលគ្នានៃធុរកិច្ចនេះ ពិតជាត្រឹមត្រូវប្រាកដមែន។

អាស្រ័យដូចបានគោរពជម្រាបជូនខាងលើ សូម **ឯកឧត្តមរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម និងជាប្រធានគណៈកម្មាធិការប្រកួតប្រជែងកម្ពុជា** មេត្តាពិនិត្យនិងសម្រេចលើការស្នើសុំជូនដំណឹងជាក្រោយនៃការរួមបញ្ចូលគ្នានៃធុរកិច្ចរបស់ខ្ញុំបាទ/នាងខ្ញុំ ដោយក្តីអនុគ្រោះ។

សូម **ឯកឧត្តមរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម និងជាប្រធានគណៈកម្មាធិការប្រកួតប្រជែងកម្ពុជា** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ អំពីខ្ញុំបាទ/នាងខ្ញុំ។

ថ្ងៃ..............................ខែ..............ឆ្នាំ............ .......ស័ក ព.ស.២៥៦....

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី........ខែ..........ឆ្នាំ២០......

**សហគ្រាស/ក្រុមហ៊ុន**